# ច្បាប់ចាក់ថ្នាំបង្ការរោគនៃកម្មវិធី CalWORKs

## ច្បាប់ចាក់ថ្នាំបង្ការរោគ

បើសិនជាលោកអ្នកទទួលប្រាក់ជំនួយនៅក្រោមកម្មវិធីជួយឱ្យធ្វើការនិងទទួលខុសត្រូវចំពោះកូននៃរដ្ឋកាលីហ្វ័រនីញ៉ា (California Work Opportunity and Responsibility to Kids ឬ CalWORKs) លោកអ្នកត្រូវតែផ្តល់ទៅឱ្យខណ្ឌនូវភស្តុតាងដែលថាកូនក្មេងនៅក្នុងគ្រួសាររបស់លោកអ្នកដែលមានអាយុតិចជាង៦ឆ្នាំបានទទួលនូវការចាក់ថ្នាំបង្ការរោគដោយត្រឹមត្រូវទៅតាមអាយុ ។ សូមមើលនៅក្នុងជួរទី២អំពីបញ្ជីនៃការចាក់ថ្នាំបង្ការរោគដែលឱ្យយោបល់ត្រូវធ្វើតាមពេទ្យ ហើយនិងមើលនៅក្នុងសន្លឹកដែលដាក់ភ្ជាប់ទៅជាមួយនេះ អំពីកាលវិភាគនៃការចាក់ថ្នាំបង្ការរោគដែលឱ្យយោបល់ត្រូវធ្វើ ។

## ភស្តុតាង

បើសិនជាលោកអ្នកគឺជាអ្នកដាក់ពាក្យសុំជំនួយ CalWORKs លោកអ្នកត្រូវតែផ្តល់ភស្តុតាងនៅក្នុងរវាង៣០ថ្ងៃ នៃការយល់ព្រមផ្តល់ជំនួយផ្នែកពេទ្យនៃរដ្ឋកាលីហ្វ័រនីញ៉ា (Medi-Cal) ឬនៅក្នុងរវាង៤៥ថ្ងៃចាប់តាំងពីកាលបរិច្ឆេទនៃពាក្យដាក់សុំជំនួយ CalWORKs បើសិនជាលោកអ្នកទទួលជំនួយ Medi-Cal រួចហើយ ។

បើសិនជាលោកអ្នកគឺជាអ្នកទទួលជំនួយ CalWORKs ក្នុងពេលបច្ចុប្បន្ន លោកអ្នកត្រូវតែដាក់ស្នើភស្តុតាងនៅក្នុងរវាង៤៥ថ្ងៃ បន្ទាប់ពីខណ្ឌបានជំរាបលោកអ្នកថា គេត្រូវការភស្តុតាងនៃការចាក់ថ្នាំបង្ការរោគ ។ សំរាប់ក្មេងម្នាក់ៗដែលមានអាយុតិចជាង៦ឆ្នាំ ដែលបានបញ្ចូលទៅក្នុងក្រុមគ្រួសារទទួលជំនួយ លោកអ្នកត្រូវតែដាក់ស្នើភស្តុតាងនៃការចាក់ថ្នាំបង្ការរោគនៅក្នុងរវាង៣០ថ្ងៃនៃការយល់ព្រមផ្តល់ជំនួយ Medi-Cal របស់ក្មេង ។

បើសិនជាលោកអ្នកមានបញ្ហាពិបាកនៅក្នុងការទទួលការចាក់ថ្នាំបង្ការរោគសំរាប់កូនរបស់លោកអ្នក សូមទាក់ទងទៅអ្នកកាន់សំណុំរឿងរបស់លោកអ្នកជាបន្ទាន់ ។

## ការលើកលែង

កូនក្មេងត្រូវបានលើកលែងពីច្បាប់ចាក់ថ្នាំបង្ការរោគទាំងនេះ បើសិនជាឪពុកម្តាយ ឬអ្នកថែរក្សាជាសាច់ញាតិដាក់ស្នើមកនូវ :

- សេចក្តីថ្លែងការជាលាយលក្ខណ៍អក្សរដែលបញ្ជាក់ថាក្មេងមិនគួរចាក់ថ្នាំបង្ការរោគទេ ពីព្រោះមានបញ្ហាផ្នែកពេទ្យ ។ សេចក្តីថ្លែងការនេះត្រូវតែបានចេញឱ្យពីវេជ្ជបណ្ឌិតរបស់គេ ឬពីអ្នកមានមុខវិជ្ជាជីវៈថែរក្សាផ្នែកពេទ្យដែលជាអ្នកធ្វើការនៅក្រោមការទទួលខុសត្រូវនៃវេជ្ជបណ្ឌិត ហើយដែលត្រូវតែផ្តល់មកនូវលក្ខណៈផ្នែកពេទ្យ ហើយនឹងថាតើលក្ខណៈនោះគ្រាន់តែមានបណ្តោះអាសន្ន ឬក៏ជាអចិន្ត្រៃយ៍ ។
- សេចក្តីថ្លែងការសម្បថដែលថាការចាក់ថ្នាំបង្ការរោគគឺជាអំពើផ្ទុយទៅនឹងជំនឿរបស់គាត់ ។

## ការមិនព្រមធ្វើសហការ

បើសិនជាលោកអ្នកមិនដាក់ស្នើភស្តុតាងនៃការចាក់ថ្នាំបង្ការរោគសំរាប់ក្មេងទាំងអស់ដែលមានអាយុតិចជាង៦ឆ្នាំដែលនៅក្នុងក្រុមគ្រួសារទទួលជំនួយ ប្រាក់ជំនួយរបស់លោកអ្នកនឹងត្រូវបានបន្ថយជាចំនួនស្មើទៅនឹងចំណែកនៃប្រាក់ជំនួយរបស់ឪពុកម្តាយ ឬអ្នកថែរក្សាជាសាច់ញាតិ ។ នៅពេលដែលគេបានដាក់ស្នើភស្តុតាងហើយ ចំនួនចំណែកនៃប្រាក់ជំនួយនឹងត្រូវបានផ្តល់ឱ្យវិញសំរាប់ឪពុកម្តាយ ឬអ្នកថែរក្សាជាសាច់ញាតិ ។

## ការចាក់ថ្នាំបង្ការរោគផ្នែកពេទ្យដែលបានឱ្យយោបល់ត្រូវធ្វើ

គណៈកម្មការនៃក្រុមប្រឹក្សាផ្នែកអនុវត្តនូវការចាក់ថ្នាំបង្ការរោគ (Advisory Committee on Immunization Practices), អគារសិក្សាផ្នែកពេទ្យកុមារអាមេរិកាំង (American Academy of Pediatrics), ហើយនិងអគារសិក្សាគ្រូពេទ្យប្រចាំគ្រួសារអាមេរិកាំង (American Academy of Family Physicians) ក្នុងពេលថ្មីៗនេះបានផ្តល់នូវការយល់ព្រមនូវការចាក់ថ្នាំបង្ការរោគដូចតទៅនេះ សំរាប់ក្មេងដែលមានអាយុតិចជាង៦ឆ្នាំ :

- រោគប្រគ្រីវ (Polio)
- រោគខាន់ស្លាក់ (Diphtheria), តេតាណុស (tetanus) និងក្អកមាន់ (pertussis) (DTaP or DTP)
- កញ្ជ្រិល (Measles), ក្រឡទេន (mumps), និងជម្ងឺស្អូច (rubella) (MMR)
- ការចាក់ថ្នាំបង្ការមេរោគអុតតូច (Varicella Virus Vaccine)* (សំរាប់រោគអុតតូច)
- រោគហើមថ្លើមប្រភេទB (Hepatitis B)
- រោគអេម៉ូហ្វីលីសអ៊ីនហ្វូនហ្សាប្រភេទ b (Hemophilus influenza type b) (សំរាប់ការរលាកស្រោមខួរ)

## ទីណាដែលលោកអ្នកអាចទទួលនូវការចាក់ថ្នាំបង្ការរោគ

- អ្នកផ្តល់កិច្ចថែរក្សាណាដែលព្រមទទួលបណ្ណ Medi-Cal
- គ្រូពេទ្យដែលទទួលពិនិត្យមើលជម្ងឺរបស់លោកអ្នក គឺនៅក្នុងគ្រោងការថែរក្សាសុខភាពដែលបានចាត់ចែងដោយកម្មវិធី Medi-Cal
- អគារព្យាបាលសុខភាពសាធារណៈនៃខណ្ឌ
- ប្រភពដទៃទៀតនៅក្នុងខណ្ឌរបស់លោកអ្នកដែលផ្តល់នូវការចាក់ថ្នាំបង្ការរោគដោយមិនគិតថ្លៃ ឬដោយគិតថ្លៃបន្តិចបន្តួច
- អ្នកផ្តល់កិច្ចថែរក្សានៃកម្មវិធីការពារសុខភាពនិងភាពពិការរបស់ក្មេង (Child Health and Disability Prevention ឬ CHDP) ។

## របៀបទទួលពត៌មានជាបន្ថែមទៀតអំពីការចាក់ថ្នាំបង្ការរោគ

លោកអ្នកអាចទូរស័ព្ទ :

- លេខទូរស័ព្ទចាំផ្តល់ពត៌មានអំពីការចាក់ថ្នាំបង្ការរោគជាតិ (National Immunization Information) ដែលបានរៀបចំឡើងដោយមជ្ឈមណ្ឌលការពារជម្ងឺ (Center for Disease Control ឬ CDC) ហើយនិងសមាគមសុខភាពសង្គមអាមេរិកាំង (American Social Health Association) ។ សូមទូរស័ព្ទពីថ្ងៃចន្ទរហូតទៅដល់ថ្ងៃសុក្រ នៅចន្លោះម៉ោង៩ព្រឹក និងម៉ោង៨ល្ងាច :
  - ភាសាអង់គ្លេស 1-800-232-2522
  - ភាសាអេស្ប៉ាញ៉ុល 1-800-232-0233
- កម្មវិធីចាក់ថ្នាំបង្ការរោគនៃក្រសួងសុខភាពក្នុងតំបន់របស់លោកអ្នក ឬកម្មវិធី CHDP (អាស្រ័យទៅលើខណ្ឌរបស់លោកអ្នក)

* ការចាក់ថ្នាំបង្ការរោគអុតតូចប្រហែលជាមិនអាចមានពីគ្រប់កន្លែងវេជ្ជបណ្ឌិតនោះឡើយ ។

បើសិនជាលោកអ្នកមានសំណួរអ្វីមួយ សូមទូរស័ព្ទទៅអ្នកកាន់សំណុំរឿងរបស់លោកអ្នក ។